# និន្នាការសេដ្ឋកិច្ចសង្គម

# Socio-Economic Trends

**ខែកញ្ញា ឆ្នាំ២០១៨ / September 2018**

## មាតិកា


| | ទំព័រ |
|---|---|
| **ខ្លឹមសារសង្ខេប/Executive summary** | **១** |
| **១. និន្នាការសេដ្ឋកិច្ចកម្ពុជា/Cambodia economic trends** | **៣** |
| ១.១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់/Consumer price index | ៣ |
| ១.២. វិស័យហិរញ្ញវត្ថុ/Finance | ៤ |
| ១.៣. វិស័យពាណិជ្ជកម្ម/Trade | ៥ |
| ១.៤. ការអនុវត្តថវិកា/Budget execution | ៦ |
| ១.៥. វិស័យវិនិយោគឯកជន/Private investment | ៧ |
| ១.៦. វិស័យទេសចរណ៍/Tourism | ៧ |
| ១.៧. វិស័យសំណង់/Construction | ៨ |
| **២. និន្នាការថ្លៃទំនិញសំខាន់ៗលើទីផ្សារអន្តរជាតិ/International commodity prices** | **៨** |
| ២.១. ថ្លៃប្រេងឆៅ (Crude oil price: Brent, WTI, Dubai) | ៨ |
| ២.២. ថ្លៃអង្ករ (Rice price: 5%, 25%, 100% broken) | ៨ |
| ២.៣. ថ្លៃកៅស៊ូ (Rubber price: TSR20, SGP/MYS) | ៩ |
| **៣. ឧបសម្ព័ន្ធ** | **១០** |

## ខ្លឹមសារសង្ខេប / Executive summary

**១.** សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅរាជធានីភ្នំពេញក្នុងខែកញ្ញា មានការកើនឡើង **០,៣%** ធៀបនឹងខែមុន និង **២,៦%** ធៀបនឹងខែដូចគ្នាឆ្នាំមុន។ សន្ទស្សន៍ថ្លៃទំនិញភាគច្រើនមានអត្រាកំណើនប្រហាក់ប្រហែលគ្នានឹងខែសីហាកន្លងទៅ ក្នុងនោះ សន្ទស្សន៍ថ្លៃក្រុមទំនិញអាហារនិងភេសជ្ជៈមិនមែនជាតិស្រវឹងកើន ២,៥% ធៀបនឹងខែដូចគ្នាឆ្នាំមុន, ភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់កើន ២,០%, សម្លៀកបំពាក់និងស្បែកជើងកើន ២,៧%, និងភោជនីយដ្ឋានកើន ៦,០%។ គិតត្រឹមខែកញ្ញា អតិផរណាមធ្យមប្រចាំឆ្នាំ (year average) មានអត្រា ២,៤% ទាបជាងអត្រាក្នុងខែដូចគ្នាឆ្នាំ២០១៧ ដែលមានអត្រា ៣,៣%។

**២.** គិតត្រឹមខែកញ្ញា ឆ្នាំ២០១៨ ឥណទានផ្តល់ដោយធនាគារពាណិជ្ជមានចំនួន ៧៩.៦៦១ ប៊ីលានរៀល បានកើនឡើង ២,៥% ធៀបនឹងខែមុន និងកើនឡើង ២៤,៨% ធៀបនឹង ១ឆ្នាំមុន។ ការផ្តល់ឥណទានដល់គ្រឹះស្ថានមិនបម្រើសេវាហិរញ្ញវត្ថុមានចំនួន ៦១,៧៥០ ប៊ីលានរៀល ក្នុងនោះឥណទានផ្តល់ទៅវិស័យសេវាកម្មមាន ៦៨,៨%, កសិកម្ម ១១,៩%, សំណង់ ១១,៧% និងឧស្សាហកម្ម ៧,៥%។ អត្រាការប្រាក់ធនាគារពាណិជ្ជចំពោះកម្ចីជាប្រាក់រៀល និងដុល្លារមានអត្រា ១១,៣៣% និង១១,០៨% បានកើនឡើងបន្តិចធៀបទៅនឹងខែសីហាកន្លងទៅ។

រីឯ រូបិយវត្ថុទូទៅ M2 បានកើនដល់ ៨៤.៦១១ ប៊ីលានរៀល ឬកើនឡើង ៣,១% ធៀបនឹងខែមុន (កើនឡើង ២១,៣% ធៀបនឹង ១ឆ្នាំមុន), ក្នុងនោះប្រាក់បញ្ញើជារូបិយប័ណ្ណបរទេសមានចំនួន ៧១.២៥៣ ប៊ីលានរៀល បានកើនឡើង ២,៧% ធៀបនឹងខែមុន និង ២២,៣% ធៀបនឹង ១ឆ្នាំមុន។

**៣.** ក្នុងខែកញ្ញា ឆ្នាំ២០១៨ តម្លៃជួញដូរលើទីផ្សារមូលបត្រកម្ពុជា (CSX) មានចំនួន ២១៦ លានរៀល បានថយចុះប្រមាណ ៤៥% ធៀបទៅនឹងខែសីហាកន្លងទៅ ដែលមានតម្លៃជួញដូរ ៣៩៥ លានរៀល។

**៤.** ទំហំទឹកប្រាក់នាំចេញសរុបនៅក្នុងរយៈពេល ៩ខែ ឆ្នាំ២០១៨ មានប្រមាណ ៩.៦៣៩ លានដុល្លារ ឬបានកើនឡើង ១៦,៧% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។ ក្នុងនោះ ទំហំទឹកប្រាក់ការនាំចេញទៅកាន់ទីផ្សារជប៉ុនមានចំនួនប្រមាណ ៨០៥ លានដុល្លារ, ទីផ្សារអាមេរិកចំនួន ២.២៨០ លានដុល្លារ, ទីផ្សារសហគមន៍អឺរ៉ុបចំនួន ២.៧៨៤ លានដុល្លារ, ទីផ្សារអង់គ្លេសចំនួន ៨៨៧ លានដុល្លារ, ទីផ្សារអាស៊ានចំនួន ៧៤០ លានដុល្លារ និងទីផ្សារផ្សេងទៀតចំនួន ២.១៤៣ លានដុល្លារ។ ចំណែកឯ ទំហំទឹកប្រាក់នាំចូលសរុបមានចំនួនប្រមាណ ១២.៦៧០ លានដុល្លារ ខ្ពស់ជាងរយៈពេលដូចគ្នាឆ្នាំមុន ២៤,៣% ដែលការកើនឡើងខ្ពស់នេះត្រូវបានចូលរួមចំណែកពីកំណើនការនាំចូលបរិក្ខារសំណង់, វាយនភ័ណ្ឌ, គ្រឿងយន្ត, ប្រេងឥន្ធនៈ និងផលិតផលហូបចុកនិងប្រើប្រាស់ផ្សេងៗ។

**៥.** តាមរយៈទិន្នន័យបណ្តោះអាសន្នពីរតនាគារជាតិ, គិតត្រឹមរយៈពេល ៩ខែ ឆ្នាំ២០១៨ រដ្ឋបាលថ្នាក់ជាតិអនុវត្តចំណូលសរុបបានចំនួន ១៤.១០៨,១៤ ប៊ីលានរៀល បានកើនឡើង ១៤,៤% បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន ក្នុងនោះ ពន្ធប្រយោលបានកើនឡើង ២២,៥%, ពាណិជ្ជកម្មក្រៅប្រទេសបានកើនឡើង ១៩,២% និងចំណូលមិនមែនសារពើពន្ធកើនឡើង ១០,៩%។ ចំណែកឯ ការអនុវត្តចំណាយបានចំនួន ១៣.៣៩២,២ ប៊ីលានរៀល ក្នុងនោះ ចំណាយចរន្តអនុវត្តបានចំនួន ៩.៨៤១,៨៣ ប៊ីលានរៀល បានកើនឡើង ១៩,៦% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។ តុល្យភាពថវិកាចរន្តមានអតិរេកសាច់ប្រាក់ចំនួន ៤.១៦៣,៣២ ប៊ីលានរៀល និងតុល្យភាពថវិកាសរុបមានអតិរេកសាច់ប្រាក់ចំនួន ៧១៥,៩៣ ប៊ីលានរៀល។

៦. រយៈពេល ៩ខែ ឆ្នាំ២០១៨ គម្រោងវិនិយោគឯកជនសរុបដែលទទួលបានការអនុញ្ញាតដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាមានចំនួន ៩៤ គម្រោង និងមានទុនវិនិយោគសរុបចំនួន ៣,៩៥៤ លានដុល្លារអាមេរិក។ ក្នុងនោះ ទុនវិនិយោគលើវិស័យកសិកម្មមានចំនួន ៩,២%, ឧស្សាហកម្មមាន ១៧,៥%, សេវាកម្មមាន ៦៦,៥% និងទេសចរណ៍មាន ៦,៨% នៃទុន-វិនិយោគសរុប។

៧. រយៈពេល ៩ខែ ឆ្នាំ២០១៨ សំណើសុំសាងសង់សរុបមាន ២.៥៤៥ គម្រោង ក្នុងនោះភាគច្រើនជាប្រភេទសំណង់លំនៅដ្ឋាន និងពាណិជ្ជកម្ម។ ក្នុងនោះ សំណង់លំនៅដ្ឋានមានចំនួន ២.១៥១ គម្រោង, សំណង់ប្រភេទពាណិជ្ជកម្មមាន ២១២ គម្រោង, សំណង់ប្រភេទទេសចរណ៍មាន ៨៦ គម្រោង, សំណង់ប្រភេទឧស្សាហកម្មមាន ៦០ គម្រោង, សំណង់ប្រភេទសាធារណៈមាន ២៩ គម្រោង និងសំណង់ប្រភេទវិនិយោគមាន ៧ គម្រោង។

៨. ក្នុងរយៈពេល ៩ខែ ឆ្នាំ២០១៨ ចំនួនមកដល់នៃភ្ញៀវទេសចរអន្តរជាតិសរុបមានចំនួនប្រមាណជាង ៤លាននាក់ បានកើនឡើង ១១,៨% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន ដែលភ្ញៀវទេសចរជនជាតិចិននៅតែបន្តនាំមុខគេ មានចំនួនប្រមាណ ៣២,៩% ធៀបនឹងចំនួនភ្ញៀវទេសចរសរុប, ចំណាត់ថ្នាក់ទីពីរ គឺអ្នកដំណើរពីវៀតណាម (១៣,៤%) និងបន្តបន្ទាប់ រួមមាន ឡាវ, កូរ៉េ, ថៃ, អាមេរិក,ជប៉ុន, បារាំង, អង់គ្លេស និងម៉ាឡេស៊ី ជាដើម។

៩. ក្នុងខែកញ្ញា ឆ្នាំ២០១៨ ប្រេងឆៅ **(Brent)** ថ្លៃ ៨២,៧៣ ដុល្លារ/បារ៉ែល កើនថ្លៃ ៤,៧ដុល្លារ/បារ៉ែល ធៀបនឹងខែមុន។ សង្កេតឃើញថា តម្រូវការប្រេងឆៅនៅឥណ្ឌា, ចិន, តួកគី និងថ្លៃប្រេងឆៅលើទីផ្សារអន្តរជាតិ បានហក់ឡើងខ្លាំងបន្ទាប់ពីអាមេរិកបានអនុម័តលើការផ្អាកទិញប្រេងពីប្រទេសអ៊ីរ៉ង់ចាប់ពីខែមេសាដើមឆ្នាំនេះ, បរិមាណស្តុកប្រេងឆៅរបស់អាមេរិកមានចំនួនទាប, ភាពតានតឹងនៃគោលនយោបាយភូមិសាស្ត្រ ព្រមទាំងការបារម្ភពីកង្វះខាតការផ្គត់ផ្គង់ប្រេងសកលលោក។

អង្ករនាំចេញរបស់កម្ពុជា (ខ្ទេច ៥%) នៅតែរក្សាថ្លៃ ៤៨០ ដុល្លារ/តោន ដូចគ្នានឹងខែមុន ទោះបីជាមានការប្រកួតប្រជែងថ្លៃអង្ករនាំចេញខ្លាំងលើទីផ្សារក្នុងតំបន់ និងអន្តរជាតិក៏ដោយ។ រីឯអង្ករនាំចេញរបស់ថៃ (ខ្ទេច ៥%) ថ្លៃ ៤០៨ ដុល្លារ/តោន បានធ្លាក់ថ្លៃ ៣ ដុល្លារ/តោន ធៀបខែមុន។ ប៉ុន្តែ ទោះបីជាមានការធ្លាក់ចុះថ្លៃបន្តិចក្តី ក៏បរិមាណនាំចេញនៅតែកើនឡើងជាបន្តបន្ទាប់, គិតត្រឹមខែកញ្ញា ឆ្នាំ២០១៨នេះ បរិមាណនាំចេញអង្ករថៃសម្រេចបាន ៩៧,៣% នៃផែនការនាំចេញប្រចាំឆ្នាំ។ ចំណែកឯ អង្ករនាំចេញរបស់វៀតណាម (ខ្ទេច ៥%) ថ្លៃ ៤១០ ដុល្លារ/តោន បានកើនថ្លៃ ៥ ដុល្លារ/តោន ធៀបនឹងខែមុន ដោយសារវៀតណាមមានឧត្តមភាពខ្ពស់ក្នុងការប្រកួតប្រជែង តាមរយៈការបង្កើនបន្ថែមគុណភាពអង្ករទាំងប្រភេទអង្ករស និងអង្ករសរីរាង្គ សម្រាប់នាំចេញអង្ករទៅទីផ្សារអាហ្វ្រិក និងអាមេរិក។ (Vietnams Rice Export)

កៅស៊ូឆៅស្តង់ដារ TSR20 លើទីផ្សារអាស៊ី ថ្លៃ ១.៣៧០ ដុល្លារ/តោន ធ្លាក់ថ្លៃ ១០ដុល្លារ/តោន ធៀបនឹងខែមុន ដោយសាររងឥទ្ធិពលពីសង្គ្រាមពាណិជ្ជកម្ម។ សង្កេតឃើញថា ថ្លៃកៅស៊ូឆៅ និងការបញ្ជាទិញកៅស៊ូនៅទីផ្សារចិនសម្រាប់ផ្គត់ផ្គង់ក្នុងសង្វាក់ផលិតកម្មឧស្សាហកម្មបានធ្លាក់ចុះ ទោះបីជា Association of Natural Rubber Producing Countries បានប៉ាន់ស្មានថា ឆ្នាំ២០១៨នេះ កំណើនតម្រូវការខ្ពស់ជាងការផ្គត់ផ្គង់ក៏ដោយ។

# ៣. ឧបសម្ព័ន្ធ

## សូចនាករនាំមុខ (Leading Indicators)




Source: Min. LMUC




Source: Ministry of Tourism




Source: Customs and Excise Dept.




Source: Customs and Excise Dept.




Source: MEF & Int.




Source: MEF & Int.

# អតិផរណា រូបិយវត្ថុ និងទុនបម្រុងបរទេស (Inflation, M2 and Foreign Reserve)

**Net Foreign Reserve (Mn US$)**




Source: NBC

**Inflation (Montly)**




Source: NIS

**Inflation (Annual)**




Source: NIS

**Inflation of Main Group Items (monthly)**




Source: NIS

**Inflation of main group Items (Year on Year)**




Source: NIS

**Broad Money M2 (Bn KHR)**




Source: NBC

# អត្រាប្តូរប្រាក់ (Exchange Rate)

**Exchange rate R/100Đ and R/B**




Source: IMF

**Exchang Rate Mal-Ringgit/$ and Phi-Peso/$**




Source: IMF

**CPI and Exchange rate R/$**




Source: IMF

**Exchange rate EU Euro/US$ and Pound/US$**




Source: IMF

**Exchange rate Aus-$ and HK-$**




Source: IMF

**Exchange rate Sing-$ and Yen-$**




Source: IMF

# ធនាគារនិងទីផ្សារមូលបត្រ (Banking and Securities Market)

**Liquidity in Bn-R and in % to GDP**




Source: NBC

**NFA and NDA (Bn-R)**




Source: NBC

**Credit to private sector, CPS (Stock) and growth**




Source: NBC

**Currency outside bank, COB and foreign deposits, FD**




Source: NBC

**Credit to Private Sectors by Sector (Bn-R)**




Source: NBC

**CSX Index and Trade Value (Mn KHR)**




*Source: Cambodia Securities Exchange*

## ការអនុវត្តថវិកា (Budget)



















## វិនិយោគឯកជន និង ការបង្កើតការងារ (Investment and Employment)


CDC Approval, Fixed Assets and Growth (Mn. $)
Fixed Assets(Left scale) 000000
Growth
Source: CDC


CDC Approvals- Fixed Assets by Sectors (Mn. $)
Industries
Non- industries
Source: CDC


Number of Jobs ('000 person)
Number of Jobs
Source: CDC


Annual Private investment CDC Approval (%)
Cambodia
External
Source: CDC


CDC Approvals, Fixed assets by Sources (Mn. $)
Cambodia(Left scale)
Asean & Others (Left scale)
America&Afrique(Right scale)
Europe(Right scale)
Source: CDC


FDI and Direct Investment Abroad, 2011Q1~2017Q1
(Quarterly, USD Mn)
Foreign Direct Investment
Direct Investment Abroad (right)
Source: CEIC

# វិស័យពាណិជ្ជកម្ម (Trades)

### Import and Export (mil.US$)




Source: Customs and Excise Department

### Import and Export Growth




Source: Customs and Excise Department

### Trade Balance and CA as % GDP




Source: National Bank of Cambodia, NBC, and Customs

### Export by Main Continents (mil.US$)




Souce: Customs and Excise Department, MEF
(including foreign currency exports )

### Export by Commodity Group ( in tonnes)




Souce: Customs and Excise Department, MEF

### Export Clothing and Rubber (mil.US$)




Souce: Customs and Excise Department, MEF

## កំណត់សម្គាល់

កៅស៊ូ÷

- កៅស៊ូ TSR20: ឬហៅថាកៅស៊ូស្តង់ដារលេខ២០ រួមមានកៅស៊ូ SIR20, SMR20 និងSTR20 គឺសំដៅលើកៅស៊ូធម្មជាតិដែលមានសារធាតុផ្សេងៗទៀត២០%។ កៅស៊ូធម្មជាតិមានច្រើនប្រភេទ ក្នុងនោះកៅស៊ូដែលមានតម្រូវការប្រើប្រាស់ច្រើនជាងគេគឺកៅស៊ូស្តង់ដារ (កៅស៊ូដុំ) និងកៅស៊ូបន្ទះ។ កៅស៊ូ TSR20 ជាប្រភេទកៅស៊ូដែលបានកែច្នៃក្នុងកម្រិតខ្ពស់ ប្រើប្រាស់សម្រាប់ផលិតកម្មកង់ឡាន បំពង់ទីបជ័រ កម្រាលជ័រ ស្បែកជើងនិងអាវភ្លៀជាដើម។ កៅស៊ូប្រភេទនេះមានកម្រិតស្អិតទាប ហើយងាយលាយបញ្ចូលជាមួយសារធាតុដទៃ ដែលធ្វើឱ្យផលិតផលផលិតចេញពីកៅស៊ូនេះមានភាពរឹងមាំ ធន់និងមិនងាយសឹករិចរិល។ ប្រទេសសំខាន់ៗដែលផលិតកៅស៊ូប្រភេទនេះគឺម៉ាឡេស៊ី ថៃ ឥណ្ឌូណេស៊ី វៀតណាមនិងចិន។
- កៅស៊ូRSS (Ribbed Smoked Sheets) បែងចែកជា៦ប្រភេទគឺ ប្រភេទលេខ 1, 2, 3, 4, 5 និងប្រភេទពិសេស មានពិណលឿងនិងវេចខ្ចប់ជាបន្ទះ។ កៅស៊ូប្រភេទ RSS3 ច្រើនផលិតនៅប្រទេសថៃ ឥណ្ឌា និងឥណ្ឌូណេស៊ី ប្រើប្រាស់ជាវត្ថុធាតុសម្រាប់ផលិតសំបកកង់រថយន្ត បំពង់ទីបជ័រ និងស្បែកជើង។ កៅស៊ូប្រភេទនេះប្រើប្រាស់ក្នុងឧស្សាហកម្មផលិតសំបកកង់រថយន្ត និងដែលជាធាតុផ្សំលើស 50% នៃផលិតផល។

ប្រេងឆៅ÷

ប្រេងឆៅ Brent, WTI និង Dubai ជាប្រភេទប្រេងឆៅធុនស្រាល (Light Crude Oil) ដែលមានការទិញលក់ច្រើនជាងគេ និងជាថ្លៃមូលដ្ឋានក្នុងការទិញលក់កិច្ចសន្យាអនាគត (Future Contract)។ ប្រេងឆៅលើទីផ្សារអន្តរជាតិមានលក្ខណៈខុសគ្នាទៅតាមប្រភេទដូចជា÷ ប្រភេទប្រេងBrent ច្រើនផលិតនៅតំបន់សមុទ្រអាត្លង់ទិចខាងជើង, ប្រភេទប្រេងរបស់អាមេរិក WTI (West Texas Intermediate) និងប្រភេទប្រេងរបស់អារ៉ាប់ប៊ីសាអ៊ូឌីត Dubai។ ប្រភេទប្រេងឆៅទាំងបីមានលក្ខណៈខុសគ្នាទៅតាមកម្រិតភាពស្រាល ហើយប្រភេទប្រេងឆៅដែលមានភាពស្រាលជាងគេអាចចម្រាញ់ជាប្រេងឥន្ធនៈបានច្រើន។ API Gravity ត្រូវបានគេប្រើប្រាស់វាស់វែងភាពស្រាលនៃប្រភេទប្រេងឆៅនីមួយៗ។ ប្រភេទប្រេងដែលមានកម្រិត API Gravity កាន់តែខ្ពស់គឺជាប្រភេទប្រេងដែលកាន់តែស្រាល និងអាចចម្រាញ់ជាប្រេងឥន្ធនៈបានច្រើន។

- WTI 40o API
- Brent 38o API
- Dubai 32o API

**រៀបចំដោយ**

**នាយកដ្ឋានស្ថិតិនិងវិភាគសេដ្ឋកិច្ច**

**អគ្គនាយកដ្ឋានគោលនយោបាយ**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

*ព័ត៌មានផ្សេងៗ សូមទាក់ទងក្រុមការងារ*

*ទូរស័ព្ទលេខ៖ ០២៣ ៤២៧ ៩១៣, ០៧៧ ៨៨ ៩៩ ៩២*

*ម៉ោងធ្វើការ៖ ៧:០០ ដល់ ១១:០០ព្រឹក និង ២:០០ ដល់ ៥:០០រសៀល*

*កំណត់សម្គាល់៖*

*ចំពោះមតិដែលបានបង្ហាញក្នុងរបាយការណ៍នេះគឺជាការយល់ឃើញរបស់ក្រុមការងារនៃអគ្គនាយកដ្ឋាន។*

*ការផ្សព្វផ្សាយនេះមិនស្តែងពីការយល់ឃើញរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬរាជរដ្ឋាភិបាលកម្ពុជានោះទេ។*